# អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)







# របាយការណ៍

# សន្និសីទជាតិលើកទី៧ ស្ដីពីបរិវត្តកម្មវិស័យអប់រំ

## ក្រោមប្រធានបទ

# «ចក្ខុវិស័យអប់រំ – មើលទៅអនាគតរួមគ្នា»

## ថ្ងៃទី១១ - ១២ ខែកញ្ញា ឆ្នាំ២០២៥

គាំទ្រ និងឧបត្ថម្ភដោយ

## សូម ស្កេន QR ដើម្បីទាញយករបាយការណ៍

# មាតិកា

I. សេចក្តីផ្តើម ..... ១

គោលបំណង ..... ៣

កាលបរិច្ឆេទ ទីកន្លែង និងអ្នកចូលរួម..... ៣

ប្រធានបទសំខាន់ៗនៃសន្និសីទ ..... ៤

II. លទ្ធផលនៃដំណើរការសន្និសីទ ..... ៥

ទស្សនៈសម្រាប់ការអប់រំនៅកម្ពុជា៖ កិច្ចស្វាគមន៍ និងអាទិភាពយុទ្ធសាស្ត្រ..... ៥

កិច្ចខិតខំប្រឹងប្រែងដើម្បីការអប់រំ និងទិសដៅសម្រាប់អនាគត..... ១០

III. អនុសាសន៍ដែលទទួលបានពីសន្និសីទ..... ១៣

*1. សិទ្ធិទទួលបានការអប់រំ៖ ការជំរុញសមធម៌សម្រាប់កុមារដែលត្រូវបានរើសអើងនៅកម្ពុជា*..... ១៣

*2. ហិរញ្ញប្បទានវិស័យអប់រំឆ្ពោះទៅឆ្នាំ២០២៦៖ ការពង្រឹងប្រព័ន្ធថវិកាដើម្បីប្រសិទ្ធភាពសាលារៀន*..... ១៤

*3. សមធម៌ និងការអប់រំបរិយាបន្ន៖ ការកសាងទស្សនៈវិស័យអប់រំប្រកបដោយសមធម៌*..... ១៥

*4. ការអប់រំ និងការប្រែប្រួលអាកាសធាតុ ពីហានិភ័យទៅភាពធន់* ..... ១៧

*5. ទស្សនៈវិស័យអប់រំឌីជីថល៖ ការចាប់ផ្តើមយ៉ាងរឹងមាំនៅឆ្នាំ២០២៦ សម្រាប់ការទទួលបានការសិក្សាប្រកបដោយសមធម៌* ..... ១៨

IV. សំលេងកុមារ និងយុវជន ដោយវេទិកាសម្តែងសម្តែងសិល្បៈ ..... ១៩

V. សន្និដ្ឋាន..... ១៩

VI. របៀបវារៈកម្មវិធី .....

VII. ឧបសម្ព័ន្ធ .....

## I. សេចក្តីផ្តើម

សន្និសីទជាតិលើកទី៧ **ស្តីពីបរិវត្តកម្មវិស័យអប់រំ ក្រោមប្រធានបទ៖ «ចក្ខុវិស័យអប់រំ – មើលទៅអនាគតរួមគ្នា»**បានរៀបចំឡើងដោយ អង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) ដែលជាអង្គកាសមាជិកភាពនៃអង្គការជាតិ និងអន្តរជាតិ ចំនួន១១៨ ដែលកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជា។ ផ្អែកលើលទ្ធផលនៃសន្និសីទជាតិលើកទី៦ នៅក្នុងខែមេសា ឆ្នាំ២០២៥ ដែលមានអ្នកចូលរួមសរុបប្រមាណជាង១៩០នាក់ មកពីតំណាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ មន្ទីរអប់រំ យុវជន និងកីឡាខេត្តក្រុង ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុងស្រុកខណ្ឌ តំណាងរដ្ឋបាលក្រុង/ស្រុក អង្គការសង្គមស៊ីវិល គ្រូបង្រៀន នាយក/នាយិកា ដៃគូអភិវឌ្ឍ ម្ចាស់ជំនួយ តំណាងយុវជន អ្នកតស៊ូមតិក្នុងវិស័យអប់រំ វិស័យឯកជន និងអ្នកធ្វើការក្នុងការអភិវឌ្ឍជំនាញ ដើម្បីពិភាក្សាលើបញ្ហាសំខាន់ៗរួមមាន៖ ការអប់រំបរិយាបន្ន លទ្ធផលនៃការសិក្សារបស់សិស្ស បញ្ហាប្រឈមនឹងការបោះបង់ការសិក្សា ការទទួលបានឱកាសក្នុងការសិក្សា សមត្ថភាពគ្រូបង្រៀន និងការចូលរួមពីសហគមន៍។ កិច្ចពិភាក្សាពេលនោះបានបង្ហាញពីបញ្ហាប្រឈមសំខាន់ៗ និងទាមទារឱ្យមានការបន្តការអនុវត្ត និងការសម្របសម្រួលសម្រាប់កុមារដែលមានពិការភាព កុមារ/យុវជនក្រៅសាលា និងក្រុមដែលងាយរងគ្រោះ។ លទ្ធផលទាំងនេះ បានបញ្ជាក់ថា ខណៈពេលដែលប្រទេសកម្ពុជា មានវឌ្ឍនភាពក្នុងការរៀបចំគោលនយោបាយ ជាពិសេសតាមរយៈផែនការយុទ្ធសាស្ត្រអប់រំ កិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀត ត្រូវបន្តអនុវត្តដើម្បីប្រែក្លាយចក្ខុវិស័យនេះឱ្យក្លាយទៅជាការអនុវត្តពិតប្រាកដនៅគ្រប់កម្រិតទាំងអស់។



ខណៈពេលកម្ពុជាកំពុងវិវត្តទៅមុខដោយកត្តាជាច្រើន ដូចជាបច្ចេកវិទ្យា ប្រជាសាស្ត្រ បម្រែបម្រួលអាកាសធាតុ ការផ្លាស់ប្តូរនិន្នាការហិរញ្ញប្បទាន ជម្ងឺរាតត្បាត និងអស្ថិរភាពភូមិសាស្ត្រនយោបាយ វិស័យអប់រំដែលជាកត្តាសំខាន់ ក៏ទទួលរងផលប៉ះពាល់ផងដែរ។ ដើម្បីកម្ពស់ការអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងត្រៀមខ្លួនរួចជាស្រេច វាទាមទារឱ្យយើងផ្តោតការដោះស្រាយបញ្ហាដែលវាស្ថិតនៅខាងមុខ ហើយត្រូវត្រៀមខ្លួនរួចជាស្រេចដើម្បីប្រឈម និងដោះស្រាយ ដោយផ្តោតលើការប៉ាន់ប្រមាណមើលពីស្ថានភាពវិស័យអប់រំក្នុងប្រទេសកម្ពុជា និងសហការគ្នាក្នុងការកំណត់នូវជំហានយុទ្ធសាស្ត្របន្ទាប់ ដើម្បីធានាថាអ្នកសិក្សាទាំងអស់ត្រូវបានគាំទ្រ និងគ្មាននរណាម្នាក់ត្រូវបានទុកចោលឡើយ។

**សន្និសីទជាតិលើកទី៧ ក្រោមប្រធានបទ «ចក្ខុវិស័យអប់រំ – មើលទៅអនាគតរួមគ្នា»** នេះ គឺជាការបន្តយុទ្ធនាការរបស់ខ្លួន ដោយប្រែក្លាយការឆ្លុះបញ្ចាំងនូវលទ្ធផល និងបញ្ហាប្រឈម ទៅជាការត្រៀមខ្លួនក្នុងការរៀបចំដោះស្រាយនៅពេលខាងមុខ។ តាមរយៈកិច្ចសន្ទនាគោលនយោបាយ ការពិភាក្សាប្រកបដោយបរិយាបន្ន ជាមួយនឹងជំហានច្បាស់លាស់ ភាគីពាក់ព័ន្ធមកពីគ្រប់មជ្ឈដ្ឋានជាមួយនឹងបទពិសោធន៍ផ្សេងៗគ្នា ពីដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ រហូតដល់អ្នកកម្ពស់ចិត្តលើគោលនយោបាយជាតិ មានឱកាសដើម្បីពិភាក្សាចែករំលែក និងរៀបចំរបៀបវារៈវិស័យអប់រំ ស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ក្នុងការធានាថាប្រជាជនកម្ពុជាទាំងអស់ ទទួលបានការអប់រំប្រកបដោយបរិយាបន្ន និងសមធម៌ ជាមួយនឹងចំណេះដឹង ជំនាញ និងគុណតម្លៃ ដែលនាំទៅរកសុខភាពល្អកាយសម្បទា និងការសិក្សាពេញមួយជីវិត។

ក្រសួងអប់រំ យុវជន និងកីឡា បានពង្រឹងនូវកំណែទម្រង់របស់ខ្លួនជាច្រើន។ នៅក្នុងខែកក្កដា ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានដឹកនាំកិច្ចប្រជុំ ស្ដីពីការពិនិត្យពិភាក្សាលើសកម្មភាពអាទិភាព និងគម្រោងថវិកាឆ្នាំ២០២៦ ក្នុងកម្រិតបច្ចេកទេស លើគម្រោងផែនការចំណូល-ចំណាយថវិកាឆ្នាំ២០២៦។ ផែនការរបស់ក្រសួង ក៏សង្កត់ធ្ងន់ទៅលើវឌ្ឍនភាពដែលអាចវាស់វែងបាន ឆ្ពោះទៅរកសូចនាករគុណភាពដូចជា លទ្ធផលនៃការអនុវត្តកម្មវិធីអន្តរជាតិវាយតម្លៃការសិក្សារបស់សិស្ស (PISA) លទ្ធផលនៃកម្មវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស កម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) ការកើនឡើងនៃចំនួនចុះឈ្មោះចូលរៀន និងការកាត់បន្ថយការបោះបង់ការសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានអំពាវនាវឱ្យនាយកដ្ឋានទាំងអស់កំណត់ ឱ្យបានច្បាស់លាស់នូវអាទិភាពកម្មវិធី តម្រូវការបច្ចេកទេស និងទិសដៅនៃការអនុវត្ត។



សន្និសីទជាតិលើកទី៧ បានផ្ដល់ឱកាស សម្រាប់អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធនៅក្នុងវិស័យអប់រំ ដើម្បីសម្របសម្រួល និងរួមចំណែក ដល់កិច្ចខិតខំប្រឹងប្រែងនៃកំណែទម្រង់ជាតិទាំងនេះ។ កិច្ចសន្ទនានេះជាវេទិកា សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងការពិភាក្សា ចែករំលែកពីកង្វល់ បញ្ហាប្រឈម គោលបំណង និងគោលដៅ នៃនយោបាយផ្សេងៗ ដែលជាការអំពាវនាវរបស់ NEP ឱ្យមានការចូលរួមយ៉ាងសកម្ម និងការរួមចំណែកប្រកបដោយអត្ថន័យពីអ្នកពាក់ព័ន្ធផ្នែកអប់រំទាំងអស់ជាពិសេសអ្នកបង្កើតគោលនយោបាយ អ្នកអនុវត្ត អ្នកឃ្លាំមើល និងអ្នកទទួលផលទាំងអស់។

## គោលបំណង

គោលបំណងនៃសន្និសីទជាតិលើកទី៧ នេះគឺៈ

- ដើម្បីបង្កើតការសម្លឹងឆ្ពោះទៅមុខ តាមរយៈការសន្ទនាផ្អែកលើភស្តុតាង ដែលកំណត់ជំហានបន្ទាប់សម្រាប់ការផ្លាស់ប្តូរការអប់រំចាប់ផ្តើមនៅឆ្នាំ២០២៦ ស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨
- ដើម្បីស្វែងរកយុទ្ធសាស្ត្រ ដែលអាចអនុវត្តបានសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវបរិយាបន្ន និងគុណភាពជាពិសេសសម្រាប់កុមារដែលមានពិការភាព កុមារ/យុវជនក្រៅសាលា និងសហគមន៍ក្រីក្រ
- ដើម្បីជំរុញឱ្យមានការចូលរួមប្រកបដោយអត្ថន័យ ពីអង្គការសង្គមស៊ីវិល អ្នកផ្តល់ការអប់រំ យុវជន មាតាបិតា និងអ្នកបង្កើតគោលនយោបាយក្នុងការបង្កើតរបៀបវារៈនៃការអប់រំនៅកម្ពុជា
- ដើម្បីបង្កើតនូវអនុសាសន៍ទាក់ទងនឹងគោលនយោបាយ និងកម្មវិធីដែលអាចផ្តល់ព័ត៌មានក្នុងការរៀបចំផែនការ និងដំណើរការអនុវត្តការអប់រំថ្នាក់ជាតិ។

## កាលបរិច្ឆេទ ទីកន្លែង និងអ្នកចូលរួម

- **កាលបរិច្ឆេទ៖** ថ្ងៃទី១១ និង ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៥
- **ទីកន្លែង៖** ហ្វេកធើរី ភ្នំពេញ (The Factory Phnom Penh)
- **ចំនួនអ្នកចូលរួម និងសមាសភាព៖** សន្និសីទនេះមានអ្នកចូលរួមចំនួន ២៥២ នាក់ (ស្រី ១១៧ នាក់) តំណាងឱ្យអង្គការ/ស្ថាប័នចំនួន ១៧១ មកពី ១៦ រាជធានីខេត្ត នៃប្រទេសកម្ពុជា រួមមាន៖
  - តំណាងរដ្ឋសភាពជាតិ នៃព្រះរាជាណាចក្រកម្ពុជា
  - តំណាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  - តំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត/ក្រុង និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុងស្រុកខណ្ឌ
  - តំណាងរដ្ឋបាលក្រុង/ស្រុក តំណាងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុក/ខណ្ឌ
  - អង្គការសង្គមស៊ីវិល និងអង្គការសមាជិកភាព/អង្គការសម្ព័ន្ធភាពក្នុងវិស័យអប់រំ
  - គ្រូបង្រៀន នាយក/នាយិកាសាលារៀន និងអ្នកអនុវត្តផ្ទាល់
  - ដៃគូអភិវឌ្ឍ ម្ចាស់ជំនួយ តំណាងយុវជន និងអ្នកតស៊ូមតិក្នុងវិស័យអប់រំ
  - វិស័យឯកជន និងអ្នកធ្វើការក្នុងការអភិវឌ្ឍជំនាញ
- **របៀបវារៈ និងបទបង្ហាញ៖** សូមមើលនៅក្នុងឧបសម្ព័ន្ធ។

## ប្រធានបទសំខាន់ៗនៃសន្និសីទ




ចាប់ផ្តើមជាមួយនឹងបទបង្ហាញកម្រិតខ្ពស់ ដែលផ្តោតទៅលើទិដ្ឋភាពគោលនយោបាយអប់រំ និងវឌ្ឍនភាពរបស់ប្រទេសកម្ពុជា លើផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ ក៏ដូចជាការអនុវត្ត ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ ដើម្បីជាទុនដល់អ្នកចូលរួមក្នុងការស្វែងយល់អំពីទិសដៅកំណែទម្រង់បច្ចុប្បន្នរបស់កម្ពុជា និងការប្តេជ្ញាចិត្តជាសកល។ តំណាងអង្គការUNICEF បានធ្វើបទបង្ហាញអំពីវឌ្ឍនភាពរបស់កម្ពុជាលើផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០។



តំណាងរបស់ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើបទបង្ហាញអំពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ESP) ២០២៤-២០២៨។ ***លំអិតក្នុងឧបសម្ព័ន្ធ***

ផ្អែកលើមូលដ្ឋាននេះ សន្និសីទ បានស្វែងយល់ពីប្រធានបទសំខាន់ៗ រួមមាន៖

- សិទ្ធិកុមារ និងការអប់រំ ផ្តោតលើការលើកកម្ពស់សមធម៌សម្រាប់កុមារងាយរងគ្រោះនៅកម្ពុជា។
- ការផ្តល់ហិរញ្ញប្បទានអប់រំឆ្នាំ២០២៦ ផ្តោតលើការពង្រឹងប្រព័ន្ធថវិកាសម្រាប់ការអនុវត្តសាលារៀនកាន់តែប្រសើរឡើង និងការអនុវត្តគោលនយោបាយ។
- ការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន ផ្តោតលើការកសាងទស្សនៈវិស័យអប់រំប្រកបដោយសមធម៌ ការដោះស្រាយភាពខុសគ្នាជុំវិញពិការភាព អត្តសញ្ញាណ និងវិបត្តិ។
- ការអប់រំ និងការប្រែប្រួលអាកាសធាតុពីហានិភ័យទៅភាពធន់ ដែលផ្តោតលើគម្រោងយុទ្ធសាស្ត្រវិស័យអប់រំចាប់ផ្តើមឆ្នាំ២០២៦។
- ការអប់រំឌីជីថល ដែលផ្តោតលើទស្សនៈវិស័យអប់រំឌីជីថល ដែលនឹងចាប់ផ្តើមនៅឆ្នាំ២០២៦ សម្រាប់ការចូលរៀនប្រកបដោយសមធម៌។

## II. លទ្ធផលនៃដំណើរការសន្និសីទ

### ទស្សនៈសម្រាប់ការអប់រំនៅកម្ពុជា៖ កិច្ចស្វាគមន៍ និងអាទិភាពយុទ្ធសាស្ត្រ

*លោកស្រី ទី វ៉ូហ្សាណែត ប្រធានក្រុមប្រឹក្សាភិបាលអង្គការ NEP*

នៅក្នុងពិធីបើក លោកស្រី ទី វ៉ូហ្សាណែត ប្រធានក្រុមប្រឹក្សាភិបាលNEP បានបញ្ជាក់ថាការចូលរួម និងការសហការរៀបចំសន្និសីទជាតិនេះ ជាសក្ខីភាពនៃការរួមគ្នាដើម្បីបង្កើតអនាគតនៃការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។ វាបង្ហាញឱ្យឃើញពីបេសកកម្មរបស់ NEP ក្នុងការប្រមូលផ្តុំអង្គការសមាជិកចំនួន១១៨ ទូទាំងប្រទេស ដើម្បីគាំទ្រការអប់រំដែលមានគុណភាព និងបរិយាបន្នសម្រាប់មនុស្សគ្រប់រូប។ លោកស្រីរំលឹកថា រយៈពេល ២៣ឆ្នាំមកនេះ NEP ដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលវេទិកាសាធារណៈសំខាន់ៗ ដើម្បីភ្ជាប់សំឡេងពីមូលដ្ឋានទៅកាន់គោលនយោបាយជាតិ ផ្សព្វផ្សាយការតស៊ូមតិដោយផ្អែកលើភស្តុតាង និងលើកកម្ពស់សិទ្ធិរបស់អ្នកសិក្សាទាំងអស់ ជាពិសេសកុមារដែលមានពិការភាព ក្មេងស្រី និងកុមារដែលងាយរងគ្រោះ។ លោកស្រីលើកឡើងថា NEP មិនអាចកើតឡើងដោយខ្លួនឯងទេ ប៉ុន្តែដោយសារការប្តេជ្ញាចិត្ត និងការសហការរបស់អង្គការសមាជិក ដៃគូអភិវឌ្ឍម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធទាំងអស់។ លោកស្រីបានអំពាវនាវឱ្យបន្តដំណើរជាមួយគ្នាឆ្ពោះទៅមុខ ដើម្បីគាំទ្រគោលនយោបាយជាតិ លើកកម្ពស់សិទ្ធិការអប់រំ និងធានាថាការអប់រំនៅកម្ពុជាមានលក្ខណៈបរិយាបន្នពិតប្រាកដ។



លោកស្រី បានលើកទឹកចិត្តឱ្យសន្និសីទនេះក្លាយជាវេទិកា នៃការបង្កើតការផ្លាស់ប្តូរពិតប្រាកដ និងមានចីរភាពសម្រាប់វិស័យអប់រំកម្ពុជា និងបានអំពាវនាវឱ្យអង្គការដែលនៅមិនទាន់ជាសមាជិក ឬកំពុងពិចារណា សូមចូលរួមជាសមាជិកនៃគ្រួសារ NEP ដើម្បីរួមចំណែកជាមួយចលនាផ្សព្វផ្សាយអប់រំប្រកបដោយគុណភាព និងភាពរួមបញ្ចូលសម្រាប់គ្រប់គ្នា។ ចុងក្រោយ លោកស្រីបានបញ្ជាក់ថា NEP គឺជាគ្រួសារមួយនៃការស្តាប់ រៀន និងដឹកនាំរួមគ្នា ហើយបទពិសោធន៍របស់សមាជិកគ្រប់រូបមានតម្លៃយ៉ាងខ្ពស់ក្នុងការបង្កើតផលវិជ្ជមានសម្រាប់អនាគតការអប់រំនៅកម្ពុជា។

**ក្នុងឱកាសនេះ លោកស្រីបានស្នើសុំឱ្យក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំគ្រប់ខេត្តក្រុង ពិចារណាអំពី៖**

- ពង្រឹងការអនុវត្តគោលនយោបាយប្រកបដោយគណនេយ្យភាព ដើម្បីធានាថាកុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំដែលមានគុណភាព
- បង្កើនចំនួនគ្រូបង្រៀន និងសាលារៀននៅតំបន់ដាច់ស្រយាល
- ពង្រឹងសមត្ថភាពគ្រូបង្រៀន ពិសេសជំនាញក្នុងការបង្រៀនសិស្សមានពិការភាព និងជនជាតិដើមភាគតិច
- បង្កើនការអនុវត្តកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីផ្តល់ជំនាញបច្ចេកវិទ្យា ICT ដល់គ្រូបង្រៀន ដើម្បីមានលទ្ធភាពបង្រៀនប្រកបដោយប្រសិទ្ធភាព

- កែលម្អហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន រួមមាន បណ្ណាល័យ សម្ភារៈសិក្សា ជំរាល ស្លាកសញ្ញាសម្រាប់សិស្សមានពិការភាព បន្ទប់ទឹក សម្ភារៈអនាម័យ ទឹកស្អាត ជាដើម
- បង្កើនប្រព័ន្ធតាមដានសាលារៀន ដើម្បីកំណត់ចំនួនវត្តមានរបស់សិស្ស កំណត់ចំនួនតំបន់ដែលមានកុមារមិនបានរៀនបានខ្ពស់ កុមារបោះបង់ការសិក្សា កុមារមានពិការភាព និងកុមារជាជនជាតិដើមភាគតិច។

***Dr. Will Parks ប្រធានក្រុមការងារវិស័យអប់រំអប់រំ (ESWG) និងជាតំណាងអង្គការ UNICEF ប្រចាំកម្ពុជា***

នៅក្នុងពិធីបើកនៃសន្និសីទ ក្នុងនាមជាប្រធាន ESWG លោកមានប្រសាសន៍ថា ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិ នៃកិច្ចព្រមព្រៀងភាពជាដៃគូសហប្រតិបត្តិការនៅកម្ពុជា (Cambodia Partnership Compact) ដែលដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងបីផ្នែកសំខាន់ គឺៈការរៀនសូត្រប្រកបដោយគុណភាព ការបង្រៀនប្រកបដោយគុណភាព និងសមភាពយេនឌ័រ។ ទោះបីជាមានសមិទ្ធផលទាំងនេះក៏ដោយ លោក បានបញ្ជាក់ថាបញ្ហាប្រឈម និងគម្លាតនៅតែមានដូចជាៈ

- ភាពចាំបាច់នៃគំនិតផ្ដួចផ្ដើមក្នុងការពង្រីកសកម្មភាពអប់រំ និងធនធានដើម្បីកែលម្អលទ្ធផលនៃការរៀនសូត្ររបស់កុមារ។
- ការបង្កើនជំនាញបុគ្គលិកអប់រំក្នុងផ្នែក ICT ក្នុងការពង្រឹងការអប់រំឌីជីថលនៅកម្រិតសាលារៀន។
- ការពង្រឹងប្រព័ន្ធទិន្នន័យសម្រាប់ការធ្វើសេចក្ដីកម្ពស់ចិត្តដោយផ្អែកលើភស្តុតាង និងការបែងចែកថវិកា។



លោកបានលើកឡើង ពីការរៀបចំថវិកាតាមអាទិភាព របស់ក្រសួងសម្រាប់ឆ្នាំ២០២៦-២០២៨ ដែលឆ្លុះបញ្ចាំងនូវអ្វី ដែលប្រព័ន្ធអប់រំដោគជ័យ ទូទាំងពិភពលោកបានប្រើប្រាស់ដូចជាៈ ការផ្សារ ភ្ជាប់ការចំណាយ ទៅនឹងលទ្ធផលដែលអាចវាស់ស្ទង់បានដូចជា ពិន្ទុកម្មវិធីអន្តរជាតិនៃវង្វាយតម្លៃលទ្ធផលសិក្សា របស់សិស្ស (PISA) និងអត្រាចុះឈ្មោះចូលរៀន។ វិធីសាស្ត្រនេះ ធានាថាធនធានដែលមានកម្រិត ត្រូវបានប្រើប្រាស់ផ្ទាល់ទៅកាន់កន្លែង ដែលត្រូវការបំផុត។ វាក៏ជួយសម្រួលដល់ការធ្វើសេចក្ដីកម្ពស់ចិត្តដោយផ្អែកលើភស្តុតាង ការពង្រឹងគណនេយ្យភាព និងគាំទ្រការកែលម្អបន្តបន្ទាប់តាមរយៈការផ្សារភ្ជាប់ថវិកាទៅនឹងលទ្ធផលដែលអាចវាស់វែងបាន។

លោកក៏បានលើកឡើងអំពីការអប់រំឌីជីថល។ អប់រំឌីជីថល បង្ហាញពីឱកាសដ៏អស្ចារ្យក្នុងការឈានដល់កុមារគ្រប់រូបពីភ្នំពេញរហូតដល់ភូមិដាច់ស្រយាលបំផុត។ សារៈសំខាន់របស់វាត្រូវបានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដែលការផ្លាស់ប្តូរឌីជីថលត្រូវបានកំណត់ជាសសរសំខាន់នៃការអភិវឌ្ឍជាតិ។ ការប្តេជ្ញាចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការលើកកម្ពស់ការអប់រំឌីជីថលនៅគ្រប់កម្រិតទាំងអស់ ត្រូវបានបង្ហាញយ៉ាងច្បាស់តាមរយៈការអនុវត្តយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន និងការបង្កើតក្របខ័ណ្ឌជាតិសមត្ថភាព ICT សម្រាប់គ្រូបង្រៀន។

ភាពធន់នឹងបម្រែបម្រួលអាកាសធាតុលែងជាជម្រើសទៀតហើយ។ អាកាសធាតុមានលក្ខណៈធ្ងន់ធ្ងរ ដូចជាកំដៅខ្លាំងនៅឆ្នាំ២០២៤ ដែលបានប៉ះពាល់ដល់កម្ពុជា និងប្រទេសជាច្រើនទៀត បង្កជាការគំរាមកំហែងផ្ទាល់ដល់ប្រព័ន្ធអប់រំ។ ពួកវាបង្កគ្រោះថ្នាក់ដល់អាយុជីវិត និងសុខុមាលភាពរបស់សិស្សនិងគ្រូបង្រៀន ធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធអប់រំ និងរំខានដល់ការរៀនសូត្រ។ ស្របតាមអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡាលើការអប់រំប្រែប្រួលអាកាសធាតុ ក្រុមESWG ប្ដេជ្ញាចិត្តក្នុងការគាំទ្រដែលសមស្រប សម្រាប់ការបង្កើតប្រព័ន្ធអប់រំអាកាសធាតុឆ្លាតវៃ។ ការប្ដេជ្ញាចិត្តនេះត្រូវបានបង្ហាញតាមរយៈការចាប់ផ្ដើមគម្រោងរយៈពេល ៥ឆ្នាំដែលមានឈ្មោះថា "ការបង្កើតភាពធន់នឹងអាកាសធាតុរបស់កុមារ និងសហគមន៍តាមរយៈវិស័យអប់រំ" ដែលជាកិច្ចសហប្រតិបត្តិការរវាងក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ Save the Children ដោយមានគោលបំណងពង្រឹងភាពធន់នឹងអាកាសធាតុនៅក្នុងសាលារៀន និងការពារកុមារពីគ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងអាកាសធាតុដែលកំពុងកើនឡើងតាមរយៈបរិស្ថានសិក្សា ដែលមានសុវត្ថិភាព និងបៃតង។

លោកបន្ថែមថា នៅពេលយើងជួបជុំគ្នាឆ្នាំក្រោយ យើងនឹងវាស់ស្ទង់ភាពជោគជ័យ មិនមែនដោយការប្រជុំដែលបានធ្វើ ឬឯកសារដែលបានផលិតនោះទេ ប៉ុន្តែជាជីវិតដែលបានផ្លាស់ប្តូរ៖ សិស្សដែលមានពិការភាពរីកចម្រើននៅក្នុងថ្នាក់រៀនបរិយាបន្ន កុមារជនបទចេះជំនាញឌីជីថលដែលភ្ជាប់ពួកគេទៅនឹងឱកាសថ្មី សហគមន៍ដែលសាលារៀនរបស់ពួកគេបានក្លាយជានិមិត្តរូបនៃភាពធន់នៅពេលប្រឈមនឹងបញ្ហាប្រឈមអាកាសធាតុ និងកុមារកំពុងមានការអនុវត្តកាន់តែប្រសើរឡើងក្នុងលទ្ធផលនៃការរៀនសូត្រ។

### *ឯកឧត្តម អ៊ឹង បូរាត រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ តំណាងឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*



ក្នុងនាមថ្នាក់ដឹកនាំ ក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមកោតសរសើរ និងថ្លែងអំណរគុណដល់អង្គការ NEP និងសមាជិកទាំងអស់ ដែលជាដៃគូ សហប្រតិបត្តិការដ៏ល្អ ទាំងក្នុងការងារគោលនយោបាយការអនុវត្តកម្មវិធី/អន្តរាគមន៍ និងការដោះស្រាយ បញ្ហាប្រឈមក្នុង វិស័យអប់រំ ជាពិសេស ការផ្តល់អន្តរាគមន៍ចំគោលដៅឆ្ពោះទៅបង្កើនឱកាសស្មើគ្នា ក្នុងការទទួលបានសេវាអប់រំប្រកបដោយគុណភាពសមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិត។ ឯកឧត្តម បានចែករំលែកទស្សនៈផ្ទាល់ខ្លួន ឆ្លើយតបនឹងប្រធានបទ៖ "ចក្ខុវិស័យអប់រំ៖ មើលទៅអនាគតរួមគ្នា" ដោយផ្អែកលើការវិភាគលើសមិទ្ធផលអប់រំរយៈពេល១០ឆ្នាំ កន្លងមក ការវិភាគអំពីដំណើរការរបស់ប្រព័ន្ធអប់រំ និងបញ្ហាប្រឈម ក្នុងវិស័យអប់រំ ព្រមទាំងការស្វែងយល់ នូវឯកសារគោលនយោបាយនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ឯកសារគោលនយោបាយ របស់រាជរដ្ឋាភិបាល និងនិន្នាការអប់រំក្នុងតំបន់ និងសកលលោក មាន៤ ចំណុចដូចខាងក្រោម៖

- ប្រធានបទនៃការពិភាក្សា គឺឆ្លុះបញ្ចាំងអំពីអាទិភាព វត្ថុបំណងគោលនយោបាយ និងយុទ្ធសាស្ត្រ ព្រមទាំងកំណែទម្រង់របស់ក្រសួង ក្នុងគោលដៅធានាបានឱកាសស្មើគ្នាក្នុងការទទួលបានសេវាអប់រំ ដោយមិនទុកនរណាម្នាក់ចោល ដូចមានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំឆ្នាំ២០៣០ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨។
- ការប្រមើលមើលអំពីចក្ខុវិស័យអប់រំ មិនគ្រាន់តែជាផែនទីបង្ហាញផ្លូវប៉ុណ្ណោះទេ ប៉ុន្តែគឺជាការប្តេជ្ញាចិត្តរួមគ្នា លើការដាក់ចេញគោលនយោបាយ និងផែនការផ្អែកលើភស្តុតាង ការគិតគូរអំពីកត្តាបរិយាបន្ន និងការលើកកម្ពស់គុណភាពនៃការអប់រំ សំដៅកែលម្អលទ្ធផលនៃការសិក្សារបស់សិស្សនៅគ្រប់កម្រិត។
- ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាបានបោះជំហានទៅមុខយ៉ាងសំខាន់ក្នុងវិស័យអប់រំ។ យើងបានបង្កើនការវិនិយោគសាធារណៈក្នុងវិស័យអប់រំជាបន្តបន្ទាប់។ ជាលទ្ធផល យើងបានពង្រីកលទ្ធភាព នៃការទទួលបានការអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា និងការកាត់បន្ថយវិសមភាពនៅក្នុងការអប់រំ។ ជាមួយគ្នានេះ តាមរយៈលទ្ធផលរបស់កម្ពុជា នៅក្នុងវង្វាយតម្លៃកម្រិតតំបន់ SEA-PLM និងកម្រិតអន្តរជាតិ PISA បានធ្វើឱ្យយើងមើលឃើញអំពី វឌ្ឍនភាព បញ្ហាប្រឈម និងកំណត់បាននូវកត្តាពាក់ព័ន្ធ ដើម្បីធ្វើការកែលម្អ។
- ការវិភាគលើបញ្ហាប្រឈម ដោយឈរលើលទ្ធផលនៃការសិក្សានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែលពាក់ព័ន្ធនឹង ការងារគ្រប់គ្រងសាលារៀន សមត្ថភាពគ្រូបង្រៀន កត្តាសិស្ស កត្តាសេដ្ឋកិច្ច-សង្គម ជាពិសេសផលប៉ះពាល់នៃកត្តាខាងក្រៅ ដូចជា វិបត្តិកូវីដ១៩ ការប្រែប្រួលអាកាសធាតុ ការកើនឡើងយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល ។ល។

***ជាការឆ្លើយតប ចក្ខុវិស័យនៃការអប់រំរួមគ្នារបស់យើង គួរផ្តោតលើអាទិភាពជាយុទ្ធសាស្ត្រចំនួនបួន រួមមាន៖***

- ការតាក់តែងគោលនយោបាយ និងផែនការផ្អែកលើភស្តុតាង៖ តាមរយៈការពង្រឹងសមត្ថភាព និងភាពជាម្ចាស់ ក្នុងការងារសិក្សាស្រាវជ្រាវគោលនយោបាយ ការពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំដែលគ្រប់ជ្រុងជ្រោយ ការវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស ការសម្របសម្រួលការអនុវត្តផែនការ និងការពង្រឹងយន្តការពិនិត្យតាមដាននិងវាយតម្លៃសមិទ្ធកម្មនៅថ្នាក់ជាតិ និងក្រោមជាតិ។ ការកំណត់យកលទ្ធផលនៃការសិក្សារបស់សិស្ស ជាចំណុចគោល និងចាប់ផ្តើម ក្នុងការពិនិត្យមើលគោលនយោបាយផែនការ និងដំណើរការនៃការអប់រំ។
- ការកែលម្អសេវាអប់រំ ផ្តោតលើកត្តាបរិយាបន្ន និងគុណភាពនៃការអប់រំ៖ ដោយពិនិត្យមើលលើការផ្តល់ និងការពង្រីកសេវាអប់រំឱ្យបានដល់ក្រុមគោលដៅដែលមានតម្រូវការបំផុត ក្រោមពាក្យស្លោក គ្មានកុមារណាម្នាក់ត្រូវបានទុកចោល។ ការវិនិយោគនឹងត្រូវបានដឹកនាំដើម្បីកែលម្អការអប់រំកុមារតូច គុណភាពគ្រូបង្រៀន ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងធនធានសិក្សាឌីជីថល។ ការផ្តល់ធនធានគ្រប់គ្រាន់ និងមានគុណភាពដល់ប្រព័ន្ធអប់រំ និងសាលារៀន ការគ្រប់គ្រងនិងដំណើរការប្រព័ន្ធអប់រំ និងសាលារៀន ស្របតាមស្តង់ដាត្រឹមត្រូវ និងមានភាពធន់ និងការអនុវត្តយន្តការវាស់វែងលទ្ធផលសិក្សា ដែលរឹងមាំ និងតម្រង់ទៅរកការជួយគាំទ្រសិស្ស។
- ការលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ភាគីក្នុងការអប់រំ៖ ដោយសារការអប់រំ មិនមែនតែជាកាតព្វកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋតែឯកឯង ប៉ុន្តែសិស្ស មាតាបិតា និងសហគមន៍ សុទ្ធតែមានភារកិច្ចចូលរួម

ទាំងអស់គ្នា រាប់ទាំងការគ្រប់គ្រងនៅតាមសាលារៀន ការគាំទ្រសាលារៀន និងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការអប់រំ ។ល។

- ការបង្កើនលទ្ធផលនៃការសិក្សារបស់សិស្ស៖ ដោយផ្តោតលើឱកាសនៃការចូលរៀននៅគ្រប់កម្រិតការអប់រំកុមារតូច ការចូលរៀនត្រូវតាមអាយុ ការកាត់បន្ថយការរៀនត្រួតថ្នាក់ និងបោះបង់ការសិក្សា។ កិច្ចការទាំងនេះទាមទារនូវអន្តរាគមន៍ប្រទាក់ក្រឡាគ្នា រួមទាំងការលើកកម្ពស់អភិបាលកិច្ចសាលារៀនតាមរយៈការបន្តកែទម្រង់សាលារៀន ដោយផ្តោតលើការពង្រឹងសមិទ្ធផលដែលមានស្រាប់ ការជំរុញការបង្កើតសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ។ ការលើកកម្ពស់គ្រូបង្រៀនតាមរយៈកំណែទម្រង់ គ្រូបង្រៀន និងសាលាគរុកោសល្យ ក្នុងទិសដៅកែលម្អវិធីសាស្ត្របង្រៀន ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាជំនួយដល់ការបង្រៀននិងរៀនភាសាបរទេស និងលើកកម្ពស់ការបង្រៀន ដែលបណ្តុះសិស្សឱ្យចេះដោះស្រាយ និងផ្សារភ្ជាប់ទៅនឹងការរស់នៅប្រចាំថ្ងៃ។ កំណែទម្រង់កម្មវិធីសិក្សា និងការផ្តោតលើការបង្រៀននិងរៀនតាមបែបសតវត្សទី២១ និងការអប់រំឌីជីថល។

តាមរយៈ ការចូលរួមទាំងអស់គ្នា និងប្រមើលមើលអំពីការអប់រំនៅឆ្នាំ២០៣០ នឹងផ្តល់លទ្ធភាពឱ្យយើងទាំងអស់គ្នា បញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរួមគ្នា ក្នុងការកសាងប្រព័ន្ធអប់រំប្រកបដោយបរិយាបន្ន ភាពធន់ និងគុណភាពសម្រាប់ទាំងអស់គ្នា។ ជារួម យើងឃើញថា វិធានការ និងយន្តការជាច្រើនត្រូវបានដាក់ចេញ និងអនុវត្ត ប៉ុន្តែការធានាថា វិធានការដែលបានដាក់ចេញ ត្រូវបានប្រែក្លាយជាការអនុវត្តនៅមូលដ្ឋាន និងសាលារៀនជាកត្តាសំខាន់ដែលទាមទារឱ្យមានការយល់ដឹង ការចូលរួមគាំទ្រ និងយន្តការតាមដានច្បាស់លាស់ពីសំណាក់បុគ្គលិកអប់រំ និងភាគីពាក់ព័ន្ធទាំងអស់។






## កិច្ចខិតខំប្រឹងប្រែងដើម្បីការអប់រំ និងទិសដៅសម្រាប់អនាគត

*សុន្ទរកថាបិទសន្និសីទ ថ្លែងដោយ ឯកឧត្តម ប៉ា សុជាតិវង្ស ប្រធានគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៃរដ្ឋសភា*



ក្នុងពិធីបិទសន្និសីទជាតិលើកទី៧ ក្នុងនាមគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៃរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមបានកោតសរសើរ ចំពោះអង្គសន្និសីទដែលបានចំណាយពេលចូលរួម ដោយមានសំនួរពិភាក្សាផ្លាស់ប្តូរយោបល់គ្នា ដោយស្មារតីស្ថាបនា លើប្រធានបទទាំង៥ ជាមួយនឹងការចែករំលែក បទពិសោធន៍ ចំណេះដឹង បញ្ហាប្រឈមនានា និងការអនុវត្តល្អៗ ដែលនេះគឺជាធាតុផ្សំដ៏មានសារៈសំខាន់ ជួយដល់ការអនុវត្តគោលនយោបាយជាតិ លើវិស័យអប់រំនេះ កាន់តែទទួលបានផ្លែផ្កាបន្ថែមទៀត។

ដើម្បីកម្ពស់ឱ្យបាននូវគោលបំណងកសាងចក្ខុវិស័យ និងស្វែងរកយុទ្ធសាស្ត្រ ដែលអាចអនុវត្តបានសំរាប់ធ្វើឱ្យប្រសើរឡើងនូវបរិយាបន្ន និងគុណភាពលើវិស័យអប់រំ ជាពិសេសសំរាប់កុមារ ដែលមានពិការភាពកុមារក្រៅសាលា និងសហគមន៍ក្រីក្រ និងសហគមន៍ដាច់ស្រយាល។ ឯកឧត្តមសង្ឃឹមយ៉ាងមុតមាំថា សន្និសីទជាតិលើកទី៧ នេះ ពិតជាបានឆ្លុះបញ្ចាំងពីតថភាពគ្រប់ជ្រុងជ្រោយនៃសង្គមកម្ពុជា ក្នុងដំណើរវិវឌ្ឍន៍ឥតឈប់ឈរពីបាតដៃទទេ បានបោះជំហានយ៉ាងស្វាហាប់មកដល់វឌ្ឍនភាពគ្រប់វិស័យដូចបច្ចុប្បន្ននេះ។ ទោះបីជាយើងទាំងអស់គ្នាទទួលស្គាល់ប្រកបដោយសុទិដ្ឋិនិយម ចំពោះវឌ្ឍនភាព និងមោទនភាពនេះ ក៏ពិតមែន តែយើងនៅតែមានបញ្ហាប្រឈមជាច្រើន ដែលត្រូវរួមគ្នាដោះស្រាយ និងពុះពារឆ្លើយតបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពបន្តទៀត។ ក្នុងនោះវិស័យអប់រំ ដែលជាវិស័យគន្លឹះមួយ ក្នុងចំណោមវិស័យដទៃទៀតក៏ទាមទារឱ្យយើងរួមគ្នា ទាំងឆន្ទៈ ទាំងសកម្មភាព ដើម្បីកម្ពស់ឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្ររបស់ជាតិយើង។ ឯកឧត្តមបានបន្តថា រាជរដ្ឋាភិបាលអាណត្តិទី៧ បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលក្នុងនោះមានមុំ២ សំខាន់ ពាក់ព័ន្ធ និងវិស័យអប់រំ ដែលមុំទី១ ផ្តោតលើការអភិវឌ្ឍមូលធនមនុស្ស និងមុំ២ គឺការអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រឌីជីថល។ ឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវរបៀបវារៈកំណែទម្រង់វិស័យអប់រំ ដែលចាប់ផ្តើមពីការធ្វើកំណែទម្រង់ការប្រលងសញ្ញាបត្រទុតិយភូមិ ក្នុងឆ្នាំ២០១៣ កំណែទម្រង់សាលារៀន និងបច្ចុប្បន្នបាននឹងកំពុងអនុវត្តស្តង់ដាសាលារៀនគំរូ។



ជាមួយគ្នានេះ ឯកឧត្តមបានបញ្ជាក់ថា ដើម្បីអនុវត្តយុទ្ធសាស្ត្របញ្ចកោណឱ្យមានប្រសិទ្ធភាពខ្ពស់ ឆ្លើយតបនឹងចក្ខុវិស័យកម្ពុជា សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា បានដាក់ចេញនូវវិធានគន្លឹះចំនួន ៤ រួមមាន៖ ទី១) ការពង្រឹងអភិបាលកិច្ចសាលារៀន ទី២) ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោង-សិក្សា ឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ទី៣) ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភ ដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន និងទី៤) ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក "ភាពជាដៃគូរដ្ឋ និង សហគមន៍ ដើម្បីការអប់រំ"។ ជាមួយនេះផងដែរ ក្រសួងក៏បានដាក់ចេញនូវរបៀបវារៈកំណែទម្រង់សាលាគរុកោសល្យ ក្នុងនោះ បានកែលំអ ហេដ្ឋារចនាសម្ព័ន្ធ វិទ្យាស្ថានគរុកោសល្យ ការលើកកម្ពស់គុណវឌ្ឍិ និងគោលនយោបាយគ្រូបង្រៀន តាមរយៈការកែលំអ គោលដៅគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ការដំឡើងប្រាក់បៀវត្ស ការជំរុញឱ្យមានការទទួលស្គាល់ និងផ្ដល់តម្លៃគ្រូបង្រៀននៅក្នុងសង្គម។

***<u>ឯកឧត្តមបានចែករំលែកនូវរបៀបវារៈសំខាន់មួយចំនួន ជាមួយនឹងការរំលេចអំពីធាតុចូលសំដៅធ្វើយ៉ាងណាឱ្យវិស័យអប់រំកាន់តែមានភាពប្រសើរឡើង៖</u>***

- ការពង្រឹងគុណភាពអប់រំគ្រប់កម្រិត គឺជាអាទិភាពដំបូងបំផុត ជាពិសេសនៅកម្រិតបឋមសិក្សា ដើម្បីធានាថាសិស្សានុសិស្ស មានមូលដ្ឋានរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា ប្រកបដោយភាពជឿជាក់សំដៅឆ្លើយតបទៅនឹងភាពបន្ទាន់នៃតម្រូវការមូលធនមនុស្សដែលមានគុណភាព។
- ការពង្រឹងគុណភាពនៃការបង្រៀន ការសិក្សា ការស្រាវជ្រាវ និងការពង្រីកមុខវិជ្ជា និងជំនាញថ្មីៗនៅឧត្តមសិក្សា គឺជាអាទិភាពចម្បងមួយទៀត ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងលឿននៃសង្គមសេដ្ឋកិច្ច បច្ចុប្បន្ន និងទៅអនាគត។
- ការពង្រឹងគុណភាពអប់រំ តម្រូវឱ្យមានការពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពគ្រប់គ្រាន់ នៅតាមមន្ទីរអប់រំ យុវជន និងកីឡា និងតាមសាលារៀនគ្រប់កម្រិត ក៏ដូចជាការជំរុញនូវការចូលរួមរបស់អាណាព្យាបាល សហគមន៍ និងវិស័យឯកជនផងដែរ។
- ការពង្រឹងការបណ្ដុះបណ្ដាលគ្រូបង្រៀន និងវិធានការ ក៏ដូចជាការបន្តលើកកម្ពស់ជីវភាព សមត្ថភាព និងគុណតម្លៃរបស់គ្រូបង្រៀន ដើម្បីឱ្យស័ក្តិសមជាកម្លាំងជួរមុខរបស់កម្ពុជា ក្នុងការកសាងមូលធនមនុស្ស ឆ្ពោះទៅកម្ពស់បាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ជាពិសេសក្នុងបរិបទនៃវិស័យអប់រំតាមគន្លងប្រក្រតីភាពថ្មី។
- ក្នុងបរិបទនៃការកើនឡើងនូវការធ្វើពាណិជ្ជកាវូបនីយកម្ម និងការប្រកួតប្រជែង ដើម្បីដណ្ដើមយកនូវការចាប់អារម្មណ៍ សាលារៀនត្រូវតែមានការកែទម្រង់ជាបន្តបន្ទាប់ តាមរយៈការជំរុញការបង្កើតសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ និងការបន្តធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សានៅគ្រប់កម្រិត ដើម្បីបង្កើតបរិយាកាស

មួយ ដែលជានាថា សាលារៀន គឺជាកន្លែងដែលសិស្សានុសិស្សចង់ទៅរៀន និងដែលផ្តល់នូវចំណេះដឹង និងការអប់រំប្រកបដោយគុណភាពឆ្លើយតបទៅនឹងតម្រូវការ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។

- ការចាប់យកកាលានុវត្តភាព ដែលលេចចេញពីបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤.០ និងបរិវត្តកម្មដ៏លឿន នៃបច្ចេកវិទ្យា ពិសេសបច្ចេកវិទ្យាឌីជីថល ទាមទារឱ្យមានការលើកកំពស់ការអប់រំឌីជីថល តាមសាលារៀន និងការជំរុញនូវការចាប់យកមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEAM) ។
- យុវជន គឺជាស្នូលនៃមូលធនមនុស្សរបស់កម្ពុជា ដែលយើងចាំបាច់ត្រូវការឱ្យពួកគាត់មានសុខភាពល្អ មានគំនិតច្នៃប្រឌិតខ្ពស់ និងមានសីលធម៌ល្អ សក្តិសមជាពលរដ្ឋល្អ ក្នុងសង្គមដែលប្រកបដោយអារ្យធម៌ខ្ពស់។ ក្នុងន័យនេះ ក្រសួងយើងពិតជាមានការចាំបាច់តម្រូវបន្តលើកកំពស់សុខភាពសិក្សារបស់សិស្ស ដោយផ្សារភ្ជាប់វិស័យកីឡាទៅនឹងវិស័យអប់រំដោយជំរុញចលនា «យុវជនម្នាក់ ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត» និងផ្តល់ឱកាសឱ្យយុវជនបញ្ចេញនៅទេពកោសល្យរបស់ខ្លួន។ ទន្ទឹមនេះក៏ត្រូវផ្តោតជាសំខាន់ផងដែរ លើការអប់រំសីលធម៌ សុជីវធម៌ ការបណ្តុះទម្លាប់ និងស្មារតីគោរពច្បាប់ និងវិន័យល្អ ព្រមទាំងបណ្តុះមនសិការស្រលាញ់ ការពារវប្បធម៌ និងអត្តសញ្ញាណជាតិ។

ឯកឧត្តមសេចក្តីសង្ឃឹមថា សន្និសីទជាតិលើកទី៧ នេះ នឹងប្រែក្លាយអាទិភាពខាងលើទៅជាផែនការសកម្មភាពជាក់ស្តែង ដើម្បីកម្ពស់បាននូវគោលដៅអប់រំ ដោយមានការកំណត់ជាសូចនាករ សមិទ្ធកម្មច្បាស់លាស់។ ការសម្រេចអាទិភាព សកម្មភាព ដែលផ្តោតលើលទ្ធផល និងការអនុវត្ត ការកែទម្រង់វិស័យអប់រំដែលផ្តោតលើការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព និងបានអះអាងថា កិច្ចការទាំងនេះ ពិតជាឆ្លើយតបទៅនឹងការដ្ឋាននៃការងារកែទម្រង់សំខាន់ៗ របស់រាជរដ្ឋាភិបាលអាណត្តិទី៧ នៃរដ្ឋសភានេះ។







## III. អនុសាសន៍ដែលទទួលបានពីសន្និសីទ

*ផ្អែកលើកិច្ចពិភាក្សាតាមប្រធានបទ និងការពិភាក្សានៅក្នុងសន្និសីទទាំងមូល ជារួមសន្និសីទកំណត់បាននូវអនុសាសន៍សំខាន់ៗជាអទិភាពតាមប្រធានបទនីមួយៗ ដូចខាងក្រោម៖*

### *1. សិទ្ធិទទួលបានការអប់រំ៖ ការជំរុញសមធម៌សម្រាប់កុមារដែលត្រូវបានរើសអើងនៅកម្ពុជា*



- សម្រួលបន្ថែមលើ កាត់បន្ថយឯកសារ សម្រាប់ការចុះឈ្មោះចូលរៀន ដូចជាសំបុត្រកំណើតឱ្យកុមារទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជាអាចចុះឈ្មោះចូលរៀនបាន។
- ពង្រឹង និងពង្រីកការអប់រំបរិយាបន្ន និងថ្នាក់សមាហរណកម្ម សម្រាប់ កុមារដែលមានពិការភាពគ្រប់ជ្រុងជ្រោយ(បណ្តុះបណ្តាលគ្រូបង្រៀនបរិយាបន្ន និងអប់រំពិសេស និងសម្ភារៈគ្រប់គ្រាន់សម្រាប់សិស្សដែលមានពិការភាព) ដើម្បីឱ្យពួកគេ អាចទទួលបានសិទ្ធិក្នុងការចូលរៀនដូចកុមារដទៃទៀត តាមរយៈពង្រឹងការធ្វើផែនទីសិក្សា និងការកំណត់អត្តសញ្ញាណពិការភាព ដើម្បីកំណត់ទីតាំងរបស់កុមារ ដែលងាយស្រួលដល់ការធ្វើផែនការបង្កើតថ្នាក់សមាហរណកម្មបន្ថែមទៀត។ ពង្រីកវិធីសាស្ត្រសិក្សាប្រកបដោយបរិយាបន្ន និងផ្តោតលើកុមារ ដោយបណ្តាក់ទុនលើការបណ្តុះបណ្តាលគ្រូបង្រៀន សម្ភារៈសិក្សាដែលអាចប្រើប្រាស់បាន និងប្រព័ន្ធគាំទ្រផ្អែកលើសហគមន៍ ដែលអាចឱ្យកុមារដែលត្រូវបានរើសអើងអាចចុះឈ្មោះចូលរៀនបន្តការសិក្សា និងទទួលបានជោគជ័យនៅក្នុងសាលារៀន។
- លើកកម្ពស់ការយល់ដឹងលើគោលនយោបាយតាមរយៈ ផ្សព្វផ្សាយ ឬណែនាំឱ្យបានកាន់តែទូលំទូលាយដល់គ្រប់អ្នកពាក់ព័ន្ធ ជាពិសេសសាលារៀន សហគមន៍ និងអ្នកអាណាព្យាបាល។ ពង្រឹងការអនុវត្តគោលនយោបាយ និងគណនេយ្យភាព ដើម្បីធានាសិទ្ធិទទួលបានការអប់រំសម្រាប់កុមារទាំងអស់ ជាពិសេសកុមារដែលមានពិការភាព កុមារក្រៅសាលា កុមារជនជាតិដើមភាគតិច ជនជាតិភាគតិច និងកុមារដែលរស់នៅតំបន់ដាច់ស្រយាល ឬតំបន់ខ្វះខាត តាមរយៈការដាក់ចេញនូវគោលដៅច្បាស់លាស់ យន្តការតាមដាន និងការបែងចែកធនធានឱ្យបានគ្រប់គ្រាន់។
- បង្កើនកិច្ចសហការអន្តរវិស័យ និងយន្តការការពារកុមាររវាងក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិល និងសហគមន៍ ដើម្បីដោះស្រាយឧបសគ្គនានា ដូចជា ភាពក្រីក្រ អំពើហិង្សា ពលកម្មកុមារ ការរៀបការវ័យក្មេង និងហានិភ័យផ្សេងទៀត ដែលរារាំងកុមារមិនឱ្យទទួលបានសិទ្ធិទទួលបានការអប់រំរបស់ពួកគេ ដោយបង្កើតប្រព័ន្ធរាយការណ៍អំពីហានិភ័យដែលមានសុវត្ថិភាព រក្សាការសំងាត់ និងមេត្រីសម្រាប់កុមារដោយសហការជាមួយអង្គការសង្គមស៊ីវិល។

- រាជរដ្ឋាភិបាលគួរពន្លឿនការអនុម័តច្បាប់ស្តីពីកិច្ចការពារកុមារ។ លើសពីនេះទៀត រាជរដ្ឋាភិបាល គួរពិចារណា ក្នុងការដាក់កំហិតដល់គ្រួសារ ក្នុងការបញ្ជូនកូនទៅរៀន ព្រមទាំងការពង្រឹងការចុះល្បាតដោយនគបាល មានសមត្ថកិច្ច ដើម្បីជានាកុមារមិនបានគេចសាលា។

## 2. *ហិរញ្ញប្បទានវិស័យអប់រំឆ្ពោះទៅឆ្នាំ២០២៦៖ ការពង្រឹងប្រព័ន្ធថវិកាដើម្បីប្រសិទ្ធភាពសាលារៀន និងការអនុវត្ត គោលនយោបាយកាន់តែប្រសើរ*



- ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ការបណ្តុះបណ្តាល និងគាំទ្រផ្នែកបច្ចេកទេសជាប្រចាំ ដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលស្រុក/ខណ្ឌ នាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន។ ការបណ្តុះបណ្តាលនេះ គួរផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុ ការកម្ពស់ចិត្តស្ម័យភាពដោយផ្អែកលើភស្តុតាង គណនេយ្យភាព និងការតាមដានការប្រើប្រាស់ថវិកា។ បទពិសោធន៍ពីអង្គការសង្គមស៊ីវិលបង្ហាញថា សាលារៀនភាគច្រើន ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត យុទ្ធសាស្ត្រគ្រប់គ្រងតាមសាលារៀនបឋមសិក្សា រាជរដ្ឋាភិបាល ជាពិសេស ច្រើនធ្វើផែនការថវិកាដោយផ្អែកលើសេចក្តីណែនាំ និងឧបករណ៍ដែលផ្តល់ជូនដោយក្រសួង ដែលជារឿយៗ ការធ្វើផែនការមិនបានឆ្លុះបញ្ចាំងពេញលេញលើបញ្ហា និងតម្រូវការជាក់ស្តែងរបស់សាលារៀននោះទេ។ ដូច្នេះ ស្ថាប័នពាក់ព័ន្ធត្រូវធានាថា សាលារៀនមានសមត្ថភាពក្នុងការវិភាគបញ្ហាដែលបានកើតឡើង និងដឹងពីវិធានការដែលត្រូវឆ្លើយតបទៅនឹងបញ្ហាកើតឡើង។
- តាមការស្ទង់មតិមួយ បានបង្ហាញថា ៧៣ភាគរយ នៃគ្រូបង្រៀន នៅកម្រិតសាលាបឋមសិក្សា ចំនួន ៣៥ ក្នុងខេត្តចំនួន១០ យល់ថាថវិកាដំណើរការសាលារៀន នៅមិនទាន់គ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការជាក់ស្តែងរបស់សាលារៀន រួមទាំងមុខសញ្ញាគាំទ្រ កិច្ចដំណើរការ និងកែលម្អគុណភាពអប់រំ។ មូលនិធិដំណើរការសាលារៀនសាធារណៈ នៅមិនទាន់គ្រប់គ្រាន់លើចំណាយសំខាន់ដូចជា កិច្ចដំណើរការរដ្ឋបាល ការថែទាំ និងជួលជុលផ្សេងៗ ការចូលរៀនដោយសមធម៌ និងបង្ការការបោះបង់ សម្ភារៈរៀននិងបង្រៀន និងការកែលម្អបរិស្ថាននិងទីធ្លា ដែលជាមូលហេតុមួយ ប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្ស។ ដើម្បីដោះស្រាយបញ្ហានេះ ភាគីពាក់ព័ន្ធ គួរពិចារណាកែសម្រួលរូបមន្តបែងចែកមូលនិធិដំណើរការសាលារៀន (SOF) ដែលបច្ចុប្បន្នអនុវត្តតាមលិខិតលេខ ៨០១៥ ស.ហ.វ អ.ថ។ ត្រូវបង្កើនប្រសិទ្ធភាពក្នុងការរៀបចំថវិកាកម្រិតសាលារៀន។ រូបមន្តថ្មីគួរតែមានសមធម៌ជាងមុន ដោយផ្អែកលើបរិបទភូមិសាស្ត្រ និងសេដ្ឋកិច្ចសង្គមនៃសិស្ស (ឧទាហរណ៍ ភាពក្រីក្រ ពិការភាព លក្ខខណ្ឌតម្រូវការពិសេស) និងអាយុ និងស្ថានភាពរូបវន្តនៃហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈបរិក្ខាររបស់សាលារៀន។ ជាមួយគ្នានេះ ត្រូវបង្កើតតម្លាភាព និងប្រសិទ្ធភាពក្នុងការរៀបចំថវិកាកម្រិតសាលារៀន តាមរយៈការតម្រង់ទិសថវិកា ជាមួយអាទិភាពនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ

ឆ្នាំ២០២៤-២០២៨។ សាលាគួរអញ្ជើញមាតាបិតា តំណាងសិស្ស តំណាងសហគមន៍ និងអាជ្ញាធរមូលដ្ឋានឱ្យចូលរួមក្នុងដំណើរការរៀបចំផែនការសាលារៀន។

- រាជរដ្ឋាភិបាលបានចាត់ទុកវិស័យអប់រំជាអាទិភាពខ្ពស់ ដោយបែងចែកថវិកាធំជាងគេបំផុតនៅក្នុងថវិកាជាតិ។ ការអប់រំគឺជាសិទ្ធមូលដ្ឋាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិភាពយូរអង្វែង។ មិនថាក្នុងកាលៈទេសៈណាក៏ដោយ ថវិកាសម្រាប់ការអប់រំមិនគួរត្រូវបានកាត់បន្ថយឡើយ។ ត្រូវធានាថាកុមារគ្រប់រូបមានលទ្ធភាពទទួលបានការអប់រំ ដែលមានគុណភាពខ្ពស់ដោយចាប់ពីកម្រិតមត្តេយ្យសិក្សា រហូតដល់ថ្នាក់ទី១២។ ទោះជាយ៉ាងណា ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងគុណភាពខ្ពស់ ត្រូវបង្កើនការចំណាយសាធារណៈលើការអប់រំឱ្យបានយ៉ាងតិច ៤% នៃផលិតផលក្នុងស្រុកសរុប (GDP) ឬយ៉ាងតិច ២០% នៃថវិកាជាតិសរុប ដើម្បីធានាថាគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាល ហើយសាលារៀនបំពាក់ដោយឧបករណ៍ និងសម្ភារៈឧបទេសគ្រប់គ្រាន់។ ជាមួយគ្នានេះ ត្រូវបង្កើនមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ដើម្បីបង្កើនគុណភាពអប់រំ។

### 3. *សមធម៌ និងការអប់រំបរិយាបន្ន៖ ការកសាងទស្សនៈវិស័យអប់រំប្រកបដោយសមធម៌៖ ការដោះស្រាយវិសមភាពលើពិការភាព អត្តសញ្ញាណ និងវិបត្តិ*

- ផ្តល់អាទិភាពដល់ការអនុវត្តគោលនយោបាយ និងក្របខណ្ឌបរិយាបន្ន ដែលនិយាយចំៗអំពីតម្រូវការអប់រំរបស់កុមារដែលមានពិការភាព ជនជាតិដើមភាគតិច ជនជាតិភាគតិច និងក្រុមដែលរងផលប៉ះពាល់ដោយវិបត្តិ ជានានូវការគាំទ្រផ្នែកច្បាប់ និងស្ថាប័នសម្រាប់ការទទួលបានការអប់រំប្រកបដោយសមធម៌។
    - ជំរុញការធ្វើអត្តសញ្ញាណពិការភាពទូទាំងប្រទេសចំពោះកុមារ និងពង្រឹងលើការបង្កើត និងប្រើប្រាស់ទិន្នន័យអំពីពិការភាពសម្រាប់ការបង្កើតផែនការនានា។
    - ពង្រីកបន្ថែមនូវឧបករណ៍ជំនួយ ហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់ការបណ្តុះបណ្តាលគរុកោសល្យដល់គ្រូបង្រៀន។
    - ជំរុញឱ្យមានភាពឆ្លើយតបគ្នារវាងកម្មវិធីអប់រំពិសេស និងកម្មវិធីសិក្សា រួមទាំងការវាយតម្លៃដែលផ្តល់ភាពបត់បែន និងសម្រួលដល់ការប្រឡង។
    - បង្កើតមជ្ឈមណ្ឌលធនធាន/មជ្ឈមណ្ឌលសាលា ដើម្បីគាំទ្រការអនុវត្តរួម និងចែករំលែកឯកសារសម្រាប់គាំទ្រការបង្រៀន។
- ពង្រឹងវិធានការបរិយាបន្ននៅកម្រិតសាលារៀន និងសហគមន៍ តាមរយៈការលើកកម្ពស់ការយល់ដឹង ការផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀន កម្មវិធីសិក្សាដែលរួមបញ្ចូលទាំងអស់ សម្ភារៈសិក្សានិងបង្រៀន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីលុបបំបាត់ឧបសគ្គដល់ការចូលរួម និងសមិទ្ធផលសម្រាប់អ្នកសិក្សាដែលត្រូវបានរើសអើង។ ពង្រឹងលំហាត់គូសផែនទីសាលារៀន ដើម្បីធានាថាព័ត៌មានពាក់ព័ន្ធរបស់កុមារ ក្នុងវ័យសិក្សានៅក្នុងភូមិ មិនថាមានពិការភាព ជនជាតិដើមតិច និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេត្រូវបានកត់ត្រា។

- ការអប់រំពហុភាសា៖
    - ពង្រីកការអប់រំពហុភាសា ដើម្បីគ្របដណ្ដប់លើកុមារជនជាតិដើមភាគតិចទាំងអស់ ធានាឱ្យមានការផ្លាស់ប្ដូរដោយរលូនទៅអក្ខរកម្មភាសាខ្មែរនៅថ្នាក់ខ្ពស់។
    - ជ្រើសរើស បណ្ដុះបណ្ដាល និងរក្សាគ្រូជនជាតិដើមភាគតិច រួមទាំងបង្កើតសម្ភារៈសិក្សាជាពហុភាសា។
    - ពង្រឹងការចូលរួមរបស់សហគមន៍ និងការរួមបញ្ចូលវប្បធម៌របស់ជនជាតិដើមភាគតិច ជនជាតិភាគតិច ដើម្បីបង្កើនការចុះឈ្មោះចូលរៀន និងការបន្តការសិក្សារបស់ពួកគេចំណោមក្រុមជនជាតិដើមភាគតិច។
    - លើកកម្ពស់ការតាមដានគោលដៅ និងយន្តការគណនេយ្យភាពនៅកម្រិតស្រុក ដើម្បីតាមដានវឌ្ឍនភាពលើសមធម៌ និងបរិយាបន្ន ដោយប្រើប្រាស់ទិន្នន័យបែងចែកដើម្បីកំណត់គម្លាត ផ្ដល់ព័ត៌មានសម្រាប់ការកម្ពស់ចិត្ត និងណែនាំធនធានឆ្ពោះទៅរកក្រុមដែលជួបការលំបាកបំផុត។



- ការសិក្សាពេញមួយជីវិត និងគន្លងអាជីព ប្រកបដោយសមធម៌
    - បញ្ជ្រាបការសិក្សាបរិយាបន្ន និងការសិក្សាពេញមួយជីវិតនៅក្នុងគោលនយោបាយជាតិ ជាមួយនឹងការអនុវត្តនៅកម្រិតមូលដ្ឋាន ដោយមានកិច្ចសហការរឹងមាំពីអង្គការក្រៅរដ្ឋាភិបាល និងការផ្សព្វផ្សាយសហគមន៍។
    - កសាងសមត្ថភាពរបស់អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្នែកអប់រំ ដើម្បីតស៊ូមតិ និងផ្ដល់ការរៀនសូត្រពេញមួយជីវិត ដែលគាំទ្រដោយឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃ។
    - ពង្រីកកម្មវិធីអប់រំវិជ្ជាជីវៈ និងក្រៅប្រព័ន្ធ ដែលភ្ជាប់យុវជន និងមនុស្សពេញវ័យដែលខ្វះខាតទៅនឹងការអប់រំបន្ថែម ការបណ្ដុះបណ្ដាលជំនាញ ឬគន្លងអាជីពផ្លូវការ។
- ការរក្សាកុមារក្នុងសាលា យេនឌ័រ និងភាពធន់នឹងវិបត្តិ
    - ផ្ដល់អាហារូបករណ៍តាមគោលដៅ ការផ្ដល់អាហារដល់សាលារៀន និងការគាំទ្រការរៀនសូត្រសម្រាប់អ្នកសិក្សាដែលមានហានិភ័យនៃការបោះបង់ការសិក្សា ជាពិសេសកុមារី។
    - រួមបញ្ចូលគរុកោសល្យដែលឆ្លើយតបនឹងយេនឌ័រទៅក្នុងវគ្គបណ្ដុះបណ្ដាលគ្រូនិងកម្មវិធីសិក្សា។
    - បង្កើតកម្មវិធីជំនួយផ្លូវចិត្ត និងសង្គមសម្រាប់អ្នកសិក្សាដែលរងផលប៉ះពាល់ដោយវិបត្តិ/គ្រោះមហន្តរាយ និងបញ្ចូលការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងផែនការអប់រំ។

## *4. ការអប់រំ និងការប្រែប្រួលអាកាសធាតុ ពីហានិភ័យទៅភាពធន់៖ ការព្យាករណ៍យុទ្ធសាស្ត្រអប់រំចាប់ពីឆ្នាំ២០២៦ តទៅ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ*




• ប្រទេសកម្ពុជាជាប្រទេសមួយ ដែលកំពុងរងគ្រោះ ដោយសារបម្រែបម្រួលអាកាសធាតុ ដែលគម្រាមគំហែងដល់គ្រប់វិស័យ ក្នុងនោះក៏មានវិស័យអប់រំផងដែរ។ ទោះបីជាក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលការណ៍ និងបទដ្ឋានគតិយុត្តិយ៉ាងណាក្តី ក៏សាលារៀនជាច្រើន នៅក្នុងតំបន់ ដែលងាយរងគ្រោះនឹងអាកាសធាតុ មិនទាន់មានយន្តការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីធានាថាកុមារមានសុវត្ថិភាព ហើយការរៀនសូត្រនៅតែបន្តក្នុងអំឡុងពេលមានអាសន្ន។ ដើម្បីជំរុញការកសាងភាពធន់ក្នុង វិស័យអប់រំ ទៅនឹងហានិភ័យទាក់ទងនឹងអាកាសធាតុក្នុងវិស័យអប់រំ ត្រូវលើកកម្ពស់ និងពង្រឹងការអនុវត្តកម្មវិធីសាលារៀនកុមារមេត្រី ក្របខណ្ឌសាលារៀនសុវត្ថិភាព ដោយពង្រឹងសមាសភាព តួនាទី និងភារកិច្ច របស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងកម្រិតសាលារៀន ឬគណៈកម្មធិការ (ដែលមានការចូលរួមពីក្រុមប្រឹក្សាកុមារ គ្រូបង្រៀន មាតាបិតា និងសហគមន៍) នៅតាមតំបន់ដែលងាយរងគ្រោះ។

- របាយការណ៍ស្តីពីការពិនិត្យការចំណាយលើអាកាសធាតុរបស់កម្ពុជាឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថា វិស័យអប់រំ ក្រោមក្រសួងអប់រំយុវជន និងកីឡា មានចំណែកត្រឹមតែ 0.១% នៃចំណាយថវិកាសាធារណៈសរុបសម្រាប់ការប្រែប្រួលអាកាសធាតុ។ ការផ្តល់មូលនិធិមានកម្រិតនេះធ្វើឱ្យសាលារៀនមិនអាចកែសម្រួលហេដ្ឋារចនាសម្ព័ន្ធ ឬផ្តល់សម្ភារៈសិក្សាបន្ទាន់ ក្នុងអំឡុងពេលមានវិបត្តិអាកាសធាតុបានឡើយ។ ក្រសួងអប់រំ យុវជន និងកីឡា គួរបង្កើនមូលនិធិសម្រាប់ភាពធន់នឹងអាកាសធាតុក្នុងវិស័យអប់រំដាច់ដោយឡែក រួមទាំងវិធានការបន្សាំ ហេដ្ឋារចនាសម្ព័ន្ធសាលារៀន ដែលមានភាពធន់ ឧបករណ៍ និងសម្ភារៈបរិក្ខារ។
- គ្រូបង្រៀន និងសិស្សនៅមានសមត្ថភាពមានកម្រិតក្នុងការធ្វើសមាហរណកម្ម ការអប់រំស្តីពីបរិស្ថាន និងបម្រែបម្រួលអាកាសធាតុ ដែលកាត់បន្ថយសមត្ថភាពរបស់ប្រព័ន្ធអប់រំក្នុងការកសាងភាពធន់រយៈពេលវែង។ សូមក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ការបណ្តុះបណ្តាលគ្រូជាបន្តបន្ទាប់ ស្តីពីការអប់រំ ស្តីពីអាកាសធាតុ និងបរិស្ថាន។ ក្រៅពីនេះ ត្រូវផ្តល់ឱកាសសម្រាប់សិស្សានុសិស្ស និងគ្រូបង្រៀន (រួមទាំងសិស្សដែលមានពិការភាព) ក្នុងការអនុវត្តចំណេះដឹង តាមរយៈគំនិតផ្តួចផ្តើមដែលដឹកនាំដោយសាលារៀន ដូចជាការប្រកួតប្រជែងគម្រោងបរិស្ថាន និងយុទ្ធនាការលើកកម្ពស់ការយល់ដឹងក្នុងសាលារៀន និងសហគមន៍។

## 5. ទស្សនៈវិស័យអប់រំឌីជីថល៖ ការចាប់ផ្ដើមយ៉ាងរឹងមាំនៅឆ្នាំ២០២៦ សម្រាប់ការទទួលបានការសិក្សាប្រកបដោយសមធម៌



- បង្កើនលទ្ធភាព ក្នុងការទទួលបានការអប់រំឌីជីថល ប្រកបដោយសមធម៌ តាមរយៈការធានាឱ្យបានថា សាលារៀនទាំងអស់ រួមទាំងសាលារៀននៅតំបន់ធម្មតា តំបន់ដាច់ស្រយាល និងសហគមន៍ដែលត្រូវបានរើសអើង មានបណ្ដាញអ៊ីនធឺណិតដែលអាចទុកចិត្តបាន មានឧបករណ៍ឌីជីថល និងបរិស្ថានសិក្សាឌីជីថល ប្រកបដោយបរិយាបន្ន។
- ពង្រឹងសមត្ថភាពអ្នកអប់រំ និងអ្នកសិក្សាតាមរយៈកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ លើគរុកោសល្យឌីជីថល ជំនាញបច្ចេកវិទ្យាព័ត៌មាន ទំនាក់ទំនងនិងបច្ចេកវិទ្យា (ICT) និងការអនុវត្តការបង្រៀន ប្រកបដោយភាពច្នៃប្រឌិតដែលជួយបង្កើនលទ្ធផលសិក្សាសម្រាប់សិស្ស។ បង្កើតគោលនយោបាយ ស្ដីពីការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) ដើម្បីគាំទ្រការរៀននិងបង្រៀនរបស់គ្រូបង្រៀន និងសិស្សប្រកបដោយក្រមសីលធម៌ត្រឹមត្រូវ។
- អភិវឌ្ឍគោលនយោបាយអប់រំឌីជីថល ប្រកបដោយនិរន្តរភាព និងបរិយាបន្ន តាមរយៈការដាក់បញ្ចូលយុទ្ធសាស្ត្រសិក្សាឌីជីថលទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ គាំទ្រវិធីសាស្ត្រសិក្សាចម្រុះ និងលើកកម្ពស់ភាពជាដៃគូជាមួយរដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍ ដើម្បីធានាបាននូវផលប៉ះពាល់រយៈពេលវែង និងលទ្ធភាពធ្វើមាត្រដ្ឋាន។
- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធអប់រំឌីជីថលជាតិនៅកម្ពុជា៖
    - សហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងវិស័យឯកជន ក្នុងការពង្រីកវិសាលភាពបណ្ដាញអ៊ីនធឺណិតឱ្យមានគុណភាព ទុកចិត្តបាន ឱ្យដល់គ្រប់សាលារៀនទាំងអស់ ជាពិសេសតំបន់ជនបទ និងតំបន់ដាច់ស្រយាល។
    - ធានាឱ្យសាលារៀនមានឧបករណ៍ឌីជីថលមូលដ្ឋាន (កុំព្យូទ័រ ទូរទស្សន៍ឆ្លាតវៃ ថេបប្លេត) និងដំណោះស្រាយអគ្គិសនី ឬថាមពលព្រះអាទិត្យដែលមានតម្លៃសមរម្យ។
    - បង្កើនថវិកាជាតិសម្រាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២០២៤–២០២៨ ដោយមានការត្រួតពិនិត្យពីរដ្ឋសភា។
- វិនិយោគលើសមត្ថភាពឌីជីថល និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀន៖
    - ធ្វើឱ្យមានជាលក្ខណៈស្ថាបន ក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) ជាប្រព័ន្ធឌីជីថល តាមរយៈថ្នាលឌីជីថល ដោយកាត់បន្ថយតម្លៃនៃការបណ្ដុះបណ្ដាល។
    - កំណត់ឱ្យគ្រូបង្រៀនទាំងអស់ ត្រូវបញ្ចប់វគ្គអនឡាញ ដែលក្រសួងអប់រំ យុវជន និងកីឡាអនុម័តនៅពេលថ្នាលឌីជីថល និងធនធានឌីជីថលត្រូវបានបញ្ចប់។
    - បង្កើតក្រុមគាំទ្រ ថ្នាក់កម្រង ដើម្បីផ្ដល់ជំនួយទៅគ្រូនៅតាមសាលារៀន។

- ធានាឱ្យមានឱកាសស្មើគ្នាសម្រាប់សិស្សដែលងាយរងគ្រោះ៖
    - អាទិភាពនៃការពង្រីកថ្នាលបឋម (PLP) និងថ្នាលឌីជីថលផ្សេងៗទៀតទៅកាន់សាលារៀនដែលមានលទ្ធផលសិក្សាទាប សហគមន៍ក្រីក្រ និងកុមារក្រៅសាលា។
    - លើកទឹកចិត្តឱ្យសាលារៀន និងអាជ្ញាធរមូលដ្ឋានចូលរួមលើកទឹកចិត្តឪពុកម្តាយ និងសហគមន៍ចូលរួមផ្តល់ឧបករណ៍ឌីជីថល ដោយមានគម្រោងជំនួយពីរដ្ឋ។
